# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំពិព័រណ៍ទេសចរណ៍អង្គរអន្តរជាតិលើកទី២

## (Organizing Committee for Second AITEX 2007)

## នៅខេត្តសៀមរាប ពីថ្ងៃទី០១-០៣ ខែតុលា ឆ្នាំ២០០៧

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតជូនដំណឹងលេខ ៧៩១ សជណ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

# សម្រេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំពិព័រណ៍ទេសចរណ៍អង្គរអន្តរជាតិលើកទី២ (Organizing Committee for Second Angkor International Tourism Exchange AITEX 2007) ពីថ្ងៃទី០១-០៣ ខែតុលា ឆ្នាំ២០០៧ នៅខេត្តសៀមរាប រួមមានសមាសភាពដូចតទៅ:

| | | |
|---|---|---|
| ១- ឯកឧត្តម ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម ជុច ភឿន | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- ឯកឧត្តម ម៉ម ប៊ុនហេង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៥- ឯកឧត្តម កែវ សាវ៉ល | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៦- ឯកឧត្តម ស៊ូ ម៉ារ៉ា | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៧- ឯកឧត្តម ទី សារ៉ី | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៨- ឯកឧត្តម | តឹម គុណសម្បត្តិ | អគ្គនាយកនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ៩- ឯកឧត្តម | ទុំ ទាវីទី | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១០- ឯកឧត្តម | នេត សាវឿន | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១១- លោក | ទៅ ពិសិដ្ឋ | អភិបាលរងខេត្តសៀមរាប | សមាជិក |
| ១២- លោក | ខ្សាយ ចន្ធី | នាយករងទីចាត់ការគយ និងរដ្ឋាករ | សមាជិក |

**ប្រការ២ : គណៈកម្មការនេះមានភារកិច្ចដូចតទៅ:**

-សម្របសម្រួល និងគាំទ្រដល់ការរៀបចំពិព័រណ៍ទេសចរណ៍អង្គរអន្តរជាតិលើកទី ២ AITEX 2007 និងការសំដែងសិល្បៈ សកម្មភាព និងទស្សនីយភាពផ្សេងៗ នៅមជ្ឈមណ្ឌល Angkor COEX ខេត្តសៀមរាប ឱ្យបានជោគជ័យល្អប្រសើរ

-សហការជាមួយស្ថាប័នរដ្ឋនានា និងផ្នែកឯកជន ដើម្បីធ្វើការឃោសនា និងផ្សព្វផ្សាយអំពីព្រឹត្តិការណ៍នេះ ឱ្យបានទូលំទូលាយទាំងក្នុង និងក្រៅប្រទេស

-សម្របសម្រួលជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ

-រៀបចំសម្រួលការធ្វើដំណើរ និងទទួលស្វាគមន៍គណៈប្រតិភូ និងភ្ញៀវទេសចរដែលមកចូលរួមក្នុងព្រឹត្តិការណ៍នេះឱ្យបានល្អ

-បូកសរុបចំណូល និងចំណាយ ព្រមទាំងរាយការណ៍អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣ :** -គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិកាក្រសួងទេសចរណ៍ក្នុងការបំពេញការងារ ។

-សមាជិកនៃគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

-គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការប្រតិបត្តិ និងអនុគណៈកម្មការទ្រទ្រង់ តាមការចាំបាច់របស់ខ្លួន ដើម្បីអនុវត្ត និងគ្រប់គ្រងការងាររៀបចំពិព័រណ៍ទេសចរណ៍អង្គរអន្តរជាតិលើកទី២ AITEX 2007 ។

**ប្រការ៤ :** គណៈកម្មការនេះត្រូវចប់ភារកិច្ច និងរំសាយជាស្វ័យប្រវត្តិ នៅពេលចប់ព្រឹត្តិការណ៍នេះ ។

**ប្រការ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័ន និងអភិបាលខេត្តសៀមរាប ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-ឯកសារ-កាលប្បវត្តិ